**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ : ០៣០ / ២០ សស៣.ម

ថ្ងៃសុក្រ ៣ កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្តល់សេវាលិខិតបញ្ជាក់កិច្ចសន្យាជួលអចលនវត្ថុ និងលិខិតបញ្ជាក់ផ្ទះជួលបន្ទប់ស្នាក់នៅ នៅយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលសង្កាត់ ក្នុងរាជធានីភ្នំពេញ

**រដ្ឋបាលរាជធានីភ្នំពេញ** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋ នៅក្នុងរាជធានីភ្នំពេញ មេត្តាជ្រាបថា ដើម្បីចូលរួមចំណែកពង្រឹងការផ្តល់សេវារដ្ឋបាល ប្រកបដោយគុណភាព ប្រសិទ្ធភាព គណនេយ្យភាព តម្លាភាព ឆាប់រហ័ស និងកាន់តែកៀកជិតប្រជាពលរដ្ឋ និងធុរជន សំដៅឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅមូលដ្ឋានលើគ្រប់វិស័យ កន្លងមក រដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌទាំង១៤ និងរដ្ឋបាលសង្កាត់ទាំង១០៥ បានផ្តល់សេវារដ្ឋបាលជាច្រើនប្រភេទតាមយន្តការច្រកចេញចូលតែមួយ នៅតាមកម្រិតរដ្ឋបាលនីមួយៗ **ក្នុងនោះ ក៏មានការផ្តល់សេវាលិខិតបញ្ជាក់កិច្ចសន្យាជួលដី/ផ្ទះ/តូប/យានជំនិះ និងលិខិតបញ្ជាក់ផ្ទះជួលបន្ទប់ស្នាក់នៅ ផងដែរ នៅសាលាសង្កាត់ ប៉ុន្តែមានបងប្អូនប្រជាពលរដ្ឋមួយចំនួនតូច នៅពុំទាន់បានដឹងជ្រួតជ្រាបទូលំទូលាយអំពីការផ្តល់សេវាលិខិតបញ្ជាក់ប្រភេទនេះនៅឡើយទេ។**

ក្នុងន័យនេះ ដើម្បីពង្រឹងការផ្តល់សេវា និងផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយអំពីសេវាខាងលើ រដ្ឋបាលរាជធានីភ្នំពេញ សូមជូនដំណឹង និងណែនាំបងប្អូនប្រជាពលរដ្ឋដែលមានកិច្ចសន្យាជួលអចលនវត្ថុ (ដី/ផ្ទះ/អគារ/សំណង់/ឃ្លាំង ជាដើម) ឬ មានផ្ទះជួលបន្ទប់ស្នាក់នៅ ហើយមានបំណងចង់បញ្ជាក់កិច្ចសន្យាជួលអចលនវត្ថុ ឬ លិខិតបញ្ជាក់ផ្ទះជួលបន្ទប់ស្នាក់នៅនេះ **សូមអញ្ជើញទៅទទួលសេវាបញ្ជាក់កិច្ចសន្យាជួលអចលនវត្ថុ និងលិខិតបញ្ជាក់ផ្ទះជួលបន្ទប់ស្នាក់នៅ នៅទីតាំងសាលាសង្កាត់ដែលអចលនវត្ថុស្ថិតនៅ ស្របតាមគោលការណ៍ បែបបទ និងនីតិវិធីដែលបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន រៀងរាល់ម៉ោងធ្វើការ។**

ទទួលបានសេចក្តីជូនដំណឹងនេះ រដ្ឋបាលខណ្ឌទាំង១៤ រដ្ឋបាលសង្កាត់ទាំង១០៥ និងមន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ ត្រូវផ្សព្វផ្សាយ អនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល ៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
  *"ដើម្បីគោរពជូនជ្រាប"*
- រដ្ឋបាលខណ្ឌទាំង១៤
- មន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ
  *"ដើម្បីអនុវត្ត"*
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ
  *"ដើម្បីជួយផ្សព្វផ្សាយ"*
- ឯកសារ-កាលប្បវត្តិ

៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh